# អ្នកស្វែងរកសិទ្ធិជ្រកកោនវៀតណាម ត្រូវបានជួយសង្គ្រោះពីក្នុងព្រៃនៃប្រទេសកម្ពុជា

ក្រុមដែលយើងមើលឃើញនៅចិញ្ចើមផ្លូវម្ខាងជិតលោកស្រី វ៉ាន់-ហ៊ី លី មើលទៅដូចជាអស់សង្ឃឹម។

ម៉ុងតាញ៉ាវៀតណាមប្រាំបីនាក់ ដែលឈរក្បែររថយន្តរបស់អង្គការសហប្រជាជាតិ មើលទៅដូចជាស្ថានភាពរបស់ពួកគេដែលបានឃើញក្នុងរូបនេះស្រាប់។ ពួកគេបានដេកក្នុងព្រៃភាគឦសាននៃប្រទេសកម្ពុជាអស់រយៈពេលជិតពីរខែ ដោយរស់ពឹងលើអ្វីដែលអ្នកស្រុកផ្តល់ឲ្យ និងអ្វីដែលពួកគេអាចរកបាន។ សម្លៀកបំពាក់របស់ពួកគេមិនបានបោកគក់ទេ សក់របស់ពួកគេមានជាប់ធូលី និងកំទេចសំរាម ពេលពួកគេដេកផ្ទាល់ដីក្នុងព្រៃនោះ។ ទឹកមុខរបស់ពួកគេបានបង្ហាញពីក្តីសង្ឃឹមថាអាចគេចខ្លួនរួច ពីការមានសេរីភាពវិញ នៅពេលឃើញរថយន្តរបស់ អ.ស.ប។

ប៉ុន្តែមុនពេលគាត់ អាចផ្តល់ឲ្យពួកគេនូវការគេចខ្លួន មុនពេលមានគេជួយបុគ្គលទាំងនោះ លោកស្រី លី តំណាងការិយាល័យសិទ្ធិមនុស្ស អ.ស.ប ប្រចាំកម្ពុជា ត្រូវស្តាប់សំដីផ្ទាល់របស់ក្រុមនេះ របស់បុគ្គលម្នាក់ៗសិន ថាតើពួកគេចង់បានអ្វី។

លោកស្រី បានសួរក្រុមដែលបានលាក់ខ្លួននៅក្នុងខេត្តរតនគិរីថា "ហេតុអ្វីបានជាអ្នកឆ្លងកាត់ព្រំដែនចូលមកក្នុងប្រទេសកម្ពុជា"។ ម្នាក់បានឆ្លើយតបថា "ដើម្បីសុំសិទ្ធិជ្រកកោន។ ពួកយើងត្រូវបានគេធ្វើទុក្ខបុកម្នេញដោយសារតែការគោរពប្រតិបត្តិសាសនារបស់យើង"។

លោកស្រី លី បានសួរថា "ចុះចំពោះអ្នកផ្សេងទៀតយ៉ាងម៉េចដែរ? តើអ្នកទាំងអស់គ្នានឹងសុំសិទ្ធិជ្រកកោនដែរឬទេ?" ហើយក៏បានសួរទៅបុគ្គលម្នាក់ៗ ពួកគេម្នាក់ៗបានឆ្លើយថា "ត្រូវហើយ យើងនឹងសុំសិទ្ធិជ្រកកោន"។

លោកស្រី លី បានមានប្រសាសន៍ថា "វាធ្វើឲ្យយើងរំភើបក្នុងចិត្តណាស់"។ "នៅពេលនោះ ខ្ញុំបានដឹងថា ពួកគេមានសុវត្ថិភាពហើយ។"

ម៉ុងតាញ៉ាទាំងនេះបាននិយាយថា ពួកគេបានលាក់ខ្លួន ដោយសារតែពួកគេខ្លាចត្រូវគេចាប់ខ្លួន និងបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ។ ម៉ុងតាញ៉ាគឺជាអ្នកកាន់និកាយសាសនាមួយមិនច្បាស់លាស់ ក្នុងចំណោមកុលសម្ព័ន្ធជាតិពន្ធុប្រហែលជា ៣០ ផ្សេងទៀត ដែលជាកុលសម្ព័ន្ធភ្នំដ៏ធំមួយកាន់គ្រឹស្តសាសនា ដែលកំពុងតែប្រឈមនឹងការធ្វើទុក្ខបុកម្នេញនៅប្រទេសវៀតណាម ដោយសារតែជំនឿសាសនារបស់ពួកគេ និងដោយសារតែពួកគេនៅខាងសហរដ្ឋអាមេរិកក្នុងអំឡុងពេលសង្គ្រាម។

លោកស្រី លី បានមានប្រសាសន៍ថា ការធ្វើដំណើរស្វែងរកម៉ុងតាញ៉ាទាំងនេះ តម្រូវឲ្យយើងត្រូវមានទាំងកម្លាំងខាងការទូត និងទាំងកម្លាំងកាយផងដែរ។ ការិយាល័យសិទ្ធិមនុស្ស រួមជាមួយសហការីមកពី ឧត្តមស្នងការ

អ.ស.ប ទទួលបន្ទុកជនភៀសខ្លួន (UNHCR) បានចំណាយពេលអស់ជាច្រើនសប្តាហ៍ដើម្បីចរចារជាមួយនឹងអាជ្ញាធរនៅថ្នាក់ជាតិ និងអាជ្ញាធរថ្នាក់ខេត្ត។ អាជ្ញាធរខេត្តបានទទូចថា បេសកកម្មរួមគ្នានេះតម្រូវឲ្យមានលិខិតអនុញ្ញាតចូលទៅកាន់តំបន់ណាមួយដើម្បីស្វែងរកក្រុមដែលលាក់ខ្លួននោះ។ លោកស្រី លី មិនយល់ស្របចំពោះការលើកឡើងនេះទេ ប៉ុន្តែលោកស្រីបានទទួលស្គាល់ពីតម្រូវការជាក់ស្តែងចំពោះបេសកកម្មរួមគ្នានេះ ដើម្បីធានាឲ្យមានកិច្ចសហប្រតិបត្តិការពីសំណាក់អាជ្ញាធរមូលដ្ឋាន។

លោកស្រីបានមានប្រសាសន៍ថា "កម្ពុជាគឺជាភាគីនៃអនុសញ្ញាស្តីពីជនភៀសខ្លួន ឆ្នាំ១៩៥១ ដែលតម្រូវឲ្យអាជ្ញាធរគ្រប់លំដាប់ថ្នាក់អនុញ្ញាតឲ្យអ្នកសុំសិទ្ធិជ្រកកោនដាក់ពាក្យសុំសិទ្ធិជ្រកកោនបាន។ យើងគ្រាន់តែមានបំណងចង់ជួយឲ្យកិច្ចការនោះប្រព្រឹត្តទៅបានតែប៉ុណ្ណោះ។" ប៉ុន្តែប្រសិនជានគរបាលមូលដ្ឋានសម្រេចបញ្ជូនបុគ្គលទាំងនោះត្រឡប់ទៅវិញនោះ អញ្ចឹងទេ វាមានបញ្ហាបន្តិចបន្តួចដែរអំពីសិទ្ធិរបស់ម៉ុងតាញ៉ាទាំងនេះ។"

សហភាពអឺរ៉ុបប្រចាំកម្ពុជាបានជំរុញឲ្យក្រសួងមហាផ្ទៃសហការជាមួយ អ.ស.ប។ យើងទទួលបានការឆ្លើយតបជាវិជ្ជមានពី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃថា ប្រសិនបើរកឃើញម៉ុងតាញ៉ាទាំងនោះ លោកនឹងស្វាគមន៍កិច្ចសហប្រតិបត្តិការជាមួយ អ.ស.ប។ ដោយសារកម្លាំងនេះ ការិយាល័យសិទ្ធិមនុស្ស អ.ស.ប និង UNHCR ព្រមទាំងអគ្គនាយកដ្ឋានអន្តោប្រវេសន៍របស់ក្រសួងមហាផ្ទៃ បានចាត់បញ្ជូនបេសកកម្មមួយទៅកាន់តំបន់នោះ ដើម្បីស្វែងរកក្រុមម៉ុងតាញ៉ា។

បេសកកម្មនេះបានជួបប្រទះការរារាំងពីអាជ្ញាធរខេត្ត។ កម្លាំងសន្តិសុខមូលដ្ឋានបានបិទផ្លូវធ្វើដំណើរទៅក្នុងព្រៃដែលគេអះអាងថាមានក្រុមទាំងនោះ បាន និងកំពុងលាក់ខ្លួន ដែលជាការរារាំងដល់បេសកកម្មស្វែងរកក្រុមដែលលាក់ខ្លួនទាំងនោះ។ ជំនួបប្រជុំមួយជាមួយអភិបាលខេត្តដែលបានរងចាំដ៏យូរមកនោះ មិនបានទទួលផលផ្លែផ្កាឡើយ។ អភិបាលខេត្តនៅតែទទូចឲ្យមានលិខិតអនុញ្ញាតធ្វើបេសកកម្មនេះ។ ទន្ទឹមនឹងនេះ ប្រភពផ្សេងៗបានប្រាប់ឲ្យយើងដឹងថា ស្ថានភាពរបស់ក្រុមទាំងនោះមិនទៀងទាត់ទេ ដោយអ្នកខ្លះធ្លាក់ខ្លួនឈឺដោយជំងឺផ្សេងៗរួមមាន គ្រុនឈាម និងគ្រុនចាញ់។ នគរបាលបានបិទផ្លូវតាំងពីព្រលឹមស្រាងៗ កម្រិតលទ្ធភាពរបស់ម៉ុងតាញ៉ាក្នុងការទទួលបានស្បៀងអាហារពីអ្នកភូមិក្បែរៗនោះ។

លោកស្រីបានមានប្រសាន៍ថា "ដំបូង អ្នកភូមិទាំងនេះ មិនមានអ្វីច្រើនណាស់ណា ដើម្បីប្រាប់យើងទេ"។ "នៅពេលយើងបានឮថាពួកគេមានជំងឺ ព្រមទាំងមានការគំរាមកំហែងឥតឈប់ឈរពីការបញ្ជូនត្រឡប់ទៅវិញនោះ វាធ្វើឲ្យយើងប្រញាប់ប្រញាល់ជំរុញបេសកកម្មរបស់យើងនេះឡើង។"

ក្រុមការិយាល័យសិទ្ធិមនុស្ស អ.ស.ប រួមជាមួយមន្ត្រីមកពីក្រសួងមហាផ្ទៃរបស់រដ្ឋាភិបាល បន្តធ្វើការងារនោះ។ គេដឹងព័ត៌មាននេះតាមប្រព័ន្ធផ្សព្វផ្សាយ អង្គការមិនមែនរដ្ឋាភិបាលនានា និងអ្នកភូមិ ថា ក្រុមបេសកកម្មរួមគ្នានេះទៅទីនោះ ដើម្បីទទួលយកម៉ុងតាញ៉ាទាំងនោះ ប្រសិនជាពួកគេចេញមកបង្ហាញខ្លួន។ តាមរយៈទូរស័ព្ទអនាមិក

ពួកគេបានដឹងថា ក្រុមម៉ុងតាញ៉ាដំបូងដែលមានគ្នាប្រាំបីនាក់ អាចនឹងចេញមកបង្ហាញខ្លួននៅពេលវេលា និងកន្លែងជាក់លាក់មួយ។ ក្រុមបេសកកម្មរួមគ្នានេះ ដែលដឹកនាំផ្ទាល់ដោយ លោកស្រី លី នៅត្រង់ចំណុចនេះ បានចេញទៅជួបម៉ុងតាញ៉ាទាំងនោះ។

មិនយូរប៉ុន្មាន នៅពេលព្រឹកនោះ គេបានរកឃើញក្រុមម៉ុងតាញ៉ាដំបូងដែលមានគ្នាប្រាំបីនាក់។ យើងត្រូវចំណាយពេលច្រើនជាងមុនក្នុងការស្វែងរកក្រុមទីពីរដែលមានគ្នាចំនួនប្រាំនាក់។ នគរបាលខេត្តបានចាប់ខ្លួនពួកគេ ហើយឃុំពួកគេទុកនៅប៉ុស្តិ៍នគរបាលមួយកន្លែង។ នៅទីបំផុត ពួកគេត្រូវបានចាប់បញ្ចូលទៅក្នុងក្រុមរួម។

លោកស្រី លី មិនត្រូវបានគេប្រកាន់ទោសអ្វីសដំណើរអ្វីទេ នៅពេលគាត់បានប្រាប់ពីមូលហេតុដែលត្រូវចំណាយពេលវេលា និងខិតខំប្រឹងប្រែងច្រើន ទាំងកម្លាំងកាយ និងទាំងខាងការទូត ដើម្បីយកអ្នកទាំង ១៣ នាក់ នោះចេញពីព្រៃក្នុងប្រទេសកម្ពុជា។ លោកស្រី បានមានប្រសាសន៍ផងដែរថា យើងពិតជាមានការព្រួយបារម្ភខ្លាំងពីសុវត្ថិភាពរបស់ពួកគេ ប្រសិនជាត្រូវបានអាជ្ញាបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញនោះ ហើយវាមានសារៈសំខាន់ជានិមិត្តរូបផងដែរ។

កាលពីពេលថ្មីៗនេះ កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងដ៏ចម្រូងចម្រាសមួយជាមួយនឹងអូស្ត្រាលីដើម្បីទទួលយកជនភៀសខ្លួនដែលបច្ចុប្បន្នកំពុងឃុំខ្លួននៅលើកោះប្រទេសណូរូនៃមហាសមុទ្រប៉ាស៊ីហ្វិក។ លោកស្រី លី បានមានប្រសាសន៍ថា ការជួយសង្គ្រោះ និងការដាក់ពាក្យសុំសិទ្ធិជ្រកកោនរបស់ម៉ុងតាញ៉ា ផ្តល់ឱកាសឲ្យកម្ពុជាបញ្ជាក់ពីបំណងរបស់ខ្លួនក្នុងការគោរពអនុវត្តតាមអនុសញ្ញាស្តីពីឋានៈជនភៀសខ្លួន។

លោកស្រី លី បានមានប្រសាសន៍ថា "គេត្រូវតែយល់ថា អាជ្ញាធរមិនអាចអនុវត្តដោយរើសមុខឡើយ នៅពេលនិយាយអំពីអ្នកសុំសិទ្ធិជ្រកកោននោះ។"

លោកស្រីបានបន្ថែមទៀតថា រឿងនេះផ្តល់ឲ្យយើងនូវករណីជាក់ស្តែងមួយ ដើម្បីប្រើជាមួយអភិបាលខេត្តផ្សេងៗទៀតដែលអាចមានបំណងផងដែរ ចង់បញ្ជូនអ្នកសុំសិទ្ធិជ្រកកោនត្រឡប់ទៅវិញ មុនពេលធ្វើការសាកសួរពួកគេពីបំណងរបស់ខ្លួន ដែលជាអកុសល ករណីនេះកើតមានពេលខ្លះដែរ។ លោកស្រី បានមានប្រសាសន៍ថា ដូច្នេះវាជាឱកាសមួយក្នុងការបង្ហាញប្រាប់អាជ្ញាធរខេត្តផ្សេងៗថា ពួកគេក៏ត្រូវគោរពអនុវត្តតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិផងដែរ។

បច្ចុប្បន្ននេះ ម៉ុងតាញ៉ាទាំងនោះ កំពុងស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានជនភៀសខ្លួនរបស់ក្រសួងមហាផ្ទៃ ទន្ទឹមនឹងនេះ ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកជនភៀសខ្លួន (UNHCR) កំពុងរៀបចំកន្លែងស្នាក់នៅឲ្យពួកគេ។ សម្រាប់ការិយាល័យរបស់លោកស្រី លី ការងាររបស់ការិយាល័យនេះ បានធ្វើចប់សព្វគ្រប់ហើយ យ៉ាងហោចណាស់ក៏ករណីមួយនេះដែរ។

លោកស្រី បានមានប្រសាសន៍ថា "ខ្ញុំមិនអាចគិតថាមានមធ្យាបាយណាមួយល្អជាងនេះ ដើម្បីបញ្ចប់ការងារនេះក្នុងឆ្នាំនេះឡើយ។"

ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៤